ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខ: ...១៤១ប្រ.ក

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រង អាជីវកម្ម សេវាថតចម្លង

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

-បានឃើញអនុក្រឹត្យលេខ ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-យោងតាមការចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលដៅ គ្រប់គ្រងលើអាជីវកម្មសេវាថតចម្លងគ្រប់ប្រភេទ ក្នុងគោលបំណងដើម្បីធានាឲ្យបាននូវការគោរព និងអនុវត្តច្បាប់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

អាជីវកម្ម សេវាថតចម្លងរួមមាន៖

- សេវាថតចម្លងឯកសារគ្រប់ប្រភេទ
- សេវាថតចម្លង បោះពុម្ព លើក្រដាស់ សាច់សំពត់ ជ័រប្លាស្ទិក និងលោហធាតុគ្រប់ប្រភេទ
- សេវាថតចម្លងបទចម្រៀងនិង/ឬរូបភាពបញ្ចូលក្នុងទូរស័ព្ទឬឧបករណ៍អេឡិចត្រូនិចផងទៃទៀត។

**ប្រការ៣.-**

រាល់ការថតចម្លងឯកសារ« ផ្លូវការ »គ្រប់ប្រភេទ ដែលមានហត្ថលេខា និង ត្រារបស់អង្គភាពក្រសួង

ស្ថាប័ន មិនអនុញ្ញាតឲ្យកែឬកោសលុប អក្សរឬលេខ ដែលនាំឲ្យប៉ះពាល់ដល់ខ្លឹមសារដើមរបស់ឯកសារ ដាច់ខាត។

**ប្រការ៤.~**

មិនអនុញ្ញាតឲ្យ អាជីវករ សេវាថតចម្លង លួចថតចម្លង និងបោះពុម្ពស្នាដៃគ្រប់ប្រភេទមាន សៀវភៅ ឯកសារ គំនូរ រូបភាព និងស្នាដៃសោតទស្សន៍ដើម្បីធ្វើអាជីវកម្ម ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ។

**ប្រការ៥.~**

មិនអនុញ្ញាតឲ្យ អាជីវករ សេវាថតចម្លង ប្រើប្រាស់ទីតាំងអាជីវកម្ម សម្រាប់ផ្សព្វផ្សាយ ឬ ចែកចាយ ឯកសារដែលមានគោលដៅធ្វើវិទ្ធង្សនា ឬប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គម។

**ប្រការ៦.~**

ហាមឃាត់ដាច់ខាត រាល់ការថតចម្លង ចែកចាយរូបភាពនិង/ឬសំឡេង សម្ភារៈអាសអាភាស ( រូបថត នឹងខ្សែវីដេអូ ) តាមរយៈទូរសព្ទ ឬឧបករណ៍អេឡិចត្រូនិចដទៃទៀតក្នុងគោលដៅស្វែងរកប្រយោជន៍។

**ប្រការ៧.~**

ការបើកទីតាំងអាជីវកម្ម សេវាថតចម្លងត្រូវសុំការអនុញ្ញាតពីមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ រាជធានី ខេត្ត ឬ តាមការិយាល័យច្រកចេញចូលតែមួយនៃក្រុង ខណ្ឌ ស្រុកគោលដៅដែលបានទទួលការធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

រាល់ការអនុញ្ញាតបើកទីតាំងអាជីវកម្ម សេវាថតចម្លង ត្រូវបង់កម្រៃសេវាកម្ម ដែលកំណត់ដោយ ប្រកាសអន្តរក្រសួង រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ តាមតារាងកម្រៃសេវាកម្មរបស់ការិយាល័យច្រកចេញចូលតែមួយ នៃក្រុង ខណ្ឌ ស្រុកគោលដៅ ដែលបានទទួលការធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ៨.~**

សំណុំបែបបទនិងឯកសារចាំបាច់ផ្សេង ៗ ដែលពាក់ព័ន្ធនិងការផ្តល់សេវាថតចម្លង ត្រូវកំណត់ដោយ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ៩.~**

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ន
-គ្រប់សាលារាជធានី ខេត្ត
-ដូចប្រការ៩
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ